# ទុទ្ទុភជាតក

(រឿងទន្សាយផ្អើលផ្លែញៅ)



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធពួកអន្យតិរ្ថិយ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ទុទ្ទុភាយតិ ភទ្ទន្តេ** ដូច្នេះជាដើម ។

បានឮថា អន្យតិរ្ថិយទាំងឡាយសម្រេចការដេកលើទីបង្អែកមានបន្លា ក្នុងទីនោះៗ ជិតវត្តជេតពន ដុតកម្តៅនូវសេចក្តីព្យាយាម ៥ ប្រការ ប្រព្រឹត្តមិច្ឆាតបៈផ្សេងៗ ។ ពេលនោះ ភិក្ខុទាំងឡាយជាច្រើនត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី កាលមកកាន់វត្តជេតពន បានឃើញអន្យតិរ្ថិយទាំងនោះក្នុងរវាងផ្លូវ ហើយទៅចូលគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សារប្រយោជន៍ក្នុងការសមាទានវត្តរបស់ពួកអន្យតិរ្ថិយមានដែរទេ ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារប្រយោជន៍ក្តី សេចក្តីវិសេសក្តី ក្នុងការសមាទានវត្តរបស់អន្យតិរ្ថិយទាំងឡាយនោះ មិនមានទេ ពិតមែន (ព្រោះថា) វត្តនោះកាលជ្រើសរើស និង

ពិចារណាហើយ ប្រៀបដូចជាផ្លូវដែលមានធូលី និងដូចជាទន្សាយ (ដែលខ្លាច) សំឡេងទុំទ្រុកដូច្នោះ កាលពួកភិក្ខុទូលអង្វរអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនដឹងភាវៈដែលទន្សាយខ្លាចសំឡេងទុំទ្រុកនោះទេ សូមទ្រង់សម្ដែងដល់ខ្ញុំព្រះអង្គផង ដូច្នេះទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតកំណើតសីហៈ ចម្រើនវ័យធំហើយ រស់នៅក្នុងព្រៃ ។ ក្នុងពេលនោះ មានព្រៃត្នោតដែលលាយដោយដើមព្នៅ នៅជិតសមុទ្រទិសខាងលិច ។ ក្នុងព្រៃនោះ មានទន្សាយមួយរស់នៅខាងក្រោមដើមត្នោតមួយដើម ដែលនៅជិតដើមព្នៅ ។

ថ្ងៃមួយ ទន្សាយនោះកាន់យកអាហាររួចហើយ មកដេកខាងក្រោមស្លឹកត្នោត និងគិតថា ប្រសិនបើផែនដីនេះក្រឡាប់ តើយើងនឹងទៅទីណាហ្ន៎ ។ ក្នុងខណៈនោះ មានផ្លែព្នៅទុំមួយ ជ្រុះធ្លាក់មកលើស្លឹកត្នោត ។ ដោយសំឡេងផ្លែព្នៅនោះ សត្វទន្សាយគិតថា ផែនដីក្រឡាប់ដោយពិត ដូច្នេះទើបលោតឡើង ហើយស្ទុះបោលរត់ទៅ ដោយមិនក្រឡេកមើលក្រោយឡើយ ។ ទន្សាយដទៃឃើញទន្សាយ ដែលភ័យខ្លាចសេចក្ដីស្លាប់ កំពុងរត់ទៅដោយរហ័សនោះ ទើបសួរថា នែលោកដ៏ចម្រើន លោកខ្លាចអ្វីខ្លាំងម្ល៉េះ ទើបបោលរត់ទៅ ។ ទន្សាយនោះពោលថា នែអ្នកដ៏ចម្រើន អ្នកកុំសួរអី ។ ទន្សាយដទៃនោះក៏បោលរត់តាមខាងក្រោយហើយសួរថា នែលោក លោកនិយាយអ្វី ។ ទន្សាយនោះ មិនក្រឡេកមើលឡើយ ហើយពោលថា ផែនដីក្រឡាប់ត្រង់កន្លែងនោះ ។ សូម្បីទន្សាយដទៃនោះ ក៏រត់តាមក្រោយទន្សាយនោះ ។ ប្រព្រឹត្តទៅដូច្នេះ ទន្សាយដទៃឃើញទន្សាយនោះហើយ ក៏នាំគ្នារត់តាមទន្សាយនោះកើតទៅជាទន្សាយមួយពាន់រួមគ្នារត់ទៅតាមទន្សាយនោះ យ៉ាងនេះ ។ មានម្រឹគមួយឃើញទន្សាយទាំងនោះហើយ ក៏រួមគ្នាបោលរត់ទៅជាមួយគ្នាដែរ ។ មានជ្រូកមួយ, ខ្ទីងមួយ, ក្របីមួយ, គោព្រៃមួយ, រមាសមួយ, ខ្លាមួយ, សីហៈមួយ, ដំរីមួយ បានឃើញសត្វទាំងនោះហើយសួរថា មានរឿងអ្វី ? កាលសត្វទាំងនោះពោលថា ផែនដីក្រឡាប់ត្រង់កន្លែងនោះ

ដូច្នេះក៏បោលរត់ទៅដែរ ។ (ព្រឹត្តិការណ៍នេះ) កើតទៅជាពួកសត្វមានប្រមាណមួយយោជន៍ ដោយលំដាប់យ៉ាងនេះ ។

គ្រានោះ ព្រះពោធិសត្វឃើញពួកសត្វទាំងនោះកំពុងរត់ ទើបសួរថា មានរឿងអ្វី កាលបានស្តាប់ថា ផែនដីក្រឡាប់ត្រង់កន្លែងនោះ ទើបគិតថា ឈ្មោះថា ការក្រឡាប់ផែនដី រមែងមិនមានក្នុងទីខ្លះទេ ប្រាកដជាសត្វទាំងនេះ ស្តាប់សំឡេងអ្វីមួយមិនច្បាស់ ដោយពិត បើយើងមិនខ្វល់ខ្វាយទេ សត្វទាំងអស់នឹងវិនាស យើងនឹងឲ្យជីវិតដល់សត្វទាំងនេះ ដូច្នេះ ហើយក៏រត់ទៅកាន់ជើងភ្នំខាងមុខ ដោយសន្ទុះនៃសីហៈ រួចបន្លឺសីហនាទ ៣ ដង ។ សត្វទាំងនោះត្រូវសេចក្តីភ័យព្រោះសីហៈគំរាម ហើយត្រឡប់មកឈរនៅជាក្រុម ។ សីហពោធិសត្វក៏ចូលទៅចន្លោះសត្វទាំងនោះ ហើយសួរថា ពួកលោករត់ទៅ ដើម្បីអ្វី ។ ពួកសត្វពោលថា ផែនដីក្រឡាប់ ។ ព្រះពោធិសត្វសួរថា កាលផែនដីក្រឡាប់ អ្នកណាបានឃើញ ។ ពួកសត្វពោលថា ពួកដំរីបានដឹង ។ ព្រះពោធិសត្វក៏សួរដំរី ។ ដំរីទាំងនោះពោលថា ពួកខ្ញុំមិនដឹងទេលោក ពួកសីហៈទើបបានដឹង, សូម្បីពួកសីហៈក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកខ្លាទើបបានដឹង, សូម្បីពួកខ្លាក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួករមាសបានដឹង, សូម្បីពួករមាសក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកគោព្រៃទើបបានដឹង, សូម្បីពួកគោព្រៃក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកក្របីទើបបានដឹង, សូម្បីពួកក្របីក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកខ្ទីងទើបបានដឹង, សូម្បីពួកខ្ទីងក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកជ្រូកទើបបានដឹង, សូម្បីពួកជ្រូកក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកម្រឹគទើបបានដឹង, សូម្បីពួកម្រឹគក៏ពោលថា ពួកខ្ញុំមិនដឹងទេ ពួកទន្សាយទើបបានដឹង, កាលសួរពួកទន្សាយ ទន្សាយទាំងឡាយប្រាប់ថា ទន្សាយនេះជាអ្នកប្រាប់ ។

លំដាប់នោះ សីហពោធិសត្វក៏សួរទន្សាយនោះថា នែសម្លាញ់ បានឮយ៉ាងនេះថា អ្នកឃើញផែនដីក្រឡាប់ឬ ។ ទន្សាយនោះពោលថា បពិត្រលោកម្ចាស់ ពិតមែន គឺខ្ញុំឃើញ ។ ព្រះពោធិសត្វសួរថា អ្នកនៅកន្លែងណាទើបបានឃើញ ។ ទន្សាយពោលថា ខ្ញុំនៅក្នុងព្រៃត្នោតដែលលាយដោយដើមព្នៅ ជិតសមុទ្រទិសខាងលិច ក្នុងព្រៃនោះ ខ្ញុំដេកខាងក្រោមស្ទឹក

ត្នោត ដែលនៅជិតដើមព្នៅ ហើយបានគិតថា បើផែនដីក្រឡាប់ យើងនឹងទៅក្នុងទីណា ខណៈនោះ ស្រាប់តែឮសូរផែនដីក្រឡាប់ ទើបខ្ញុំរត់ទៅ ។

សីហពោធិសត្វគិតថា ប្រាកដជាផ្លែព្នៅទុំជ្រុះធ្លាក់លើស្លឹកត្នោតដោយពិត ហើយធ្វើឲ្យមានសំឡេងទុទ្ទុកប្រព្រឹត្តទៅ ទន្សាយនេះស្តាប់សំឡេងនោះហើយ ធ្វើសេចក្តីសម្គាល់ថា ផែនដីក្រឡាប់ ដូច្នេះទើបរត់ទៅ យើងនឹងដឹងតាមសេចក្តីពិត ។ ព្រះពោធិសត្វនាំទន្សាយនោះនិងញ៉ាំងពួកសត្វឲ្យបានធូរចិត្ត ហើយពោលថា យើងនឹងដឹងផែនដីក្រឡាប់ក្តី មិនក្រឡាប់ក្តី តាមសេចក្តីពិត ត្រង់កន្លែងដែលទន្សាយនេះបានឃើញ ហើយនឹងត្រឡប់មក ពួកលោកចូរនៅក្នុងទីនេះ ដរាបដល់ពេលដែលយើងមក ដូច្នេះហើយ ព្រះពោធិសត្វឲ្យទន្សាយឡើងជិះលើខ្នង រួចស្ទុះបោលទៅដោយសន្ទុះសីហៈ ដាក់ទន្សាយឲ្យចុះក្នុងព្រៃត្នោត រួចពោលថា ចូរមក អ្នកចូរសម្តែងកន្លែងដែលអ្នកឃើញ (ដល់យើង) ។ ទន្សាយពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនហ៊ានទេ ។ សីហពោធិសត្វពោលថា ចូរមក អ្នកកុំខ្លាចអី ។ ទន្សាយនោះមិនអាចនឹងចូលទៅកាន់ដើមព្នៅ ទើបឋិតនៅក្នុងទីមិនឆ្ងាយ ហើយពោលថា បពិត្រលោកម្ចាស់ កន្លែងនេះជាកន្លែងធ្វើសំឡេងទុទ្ទុកឲ្យប្រព្រឹត្តទៅ ដូច្នេះទើបពោលគាថាទី ១ ថា

**ទុទ្ទុភាយតិ ភទ្ទន្តេ, យស្មឹ ទេសេ វសាមហំ;**
**អហម្បេតំ ន ជានាមិ, កិមេតំ ទុទ្ទុភាយតិ ។**

***សូមសេចក្តីចម្រើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា ប្រទេសនោះធ្វើសំឡេងឮទុទ្ទុក (ឮទុក ៗ) តែខ្ញុំមិនដឹងនូវប្រទេសនុ៎ះថា អ្វីនេះ ធ្វើសំឡេងឮទុទ្ទុក ។***

កាលទន្សាយពោលយ៉ាងនេះហើយ សីហពោធិសត្វទៅកាន់គល់ដើមព្នៅ បានឃើញផ្លែព្នៅទុំដែលជ្រុះធ្លាក់លើស្លឹកត្នោត ត្រង់កន្លែងដែលទន្សាយ ដេកខាងក្រោមស្លឹកត្នោត ក៏ដឹងថា ផែនដីមិនក្រឡាប់តាមសេចក្តីពិតហើយ ឲ្យទន្សាយឡើងជិះលើខ្នង ហើយប្រញាប់ទៅកាន់សម្នាក់ពួកម្រឹគ ដោយសន្ទុះនៃសីហៈ រួចប្រាប់រឿងរ៉ាវទាំងអស់ និងពោលថា សូម

*អ្នកទាំងឡាយកុំភ័យឡើយ ដូច្នេះហើយក៏បានញ៉ាំងពួកម្រឹគឲ្យបានធូរចិត្ត រួចដោះលែងទៅ។ ប្រសិនបើក្នុងពេលនោះ មិនមានព្រះពោធិសត្វទេ សត្វទាំងអស់នឹងបោលចូលសមុទ្រ ហើយនឹងវិនាស ។ តែដោយអាស្រ័យព្រះពោធិសត្វ ពួកសត្វទាំងអស់ក៏បានមានជីវិត (តទៅ) ។*

*(ព្រះសាស្តាទ្រង់សំដែងថា)*

ពេលុវំ បតិតំ សុត្វា, ទុទ្ទុភន្តិ សសោ ជវិ;
សសស្ស វចនំ សុត្វា, សន្តត្តា មិគវាហិនី ។

*ទន្សាយឮសូរផ្លែព្នៅជ្រុះថាទុទ្ទុក ដូច្នេះ ក៏ស្ទុះបោលប្រូច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត។*

អប្បត្វា បទវិញ្ញាណំ, បរឃោសានុសារិនោ;
បនាទបរមា ពាលា, តេ ហោន្តិ បរបត្តិយា ។

*ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែកនៃសោតវិញ្ញាណ ឮសំឡេងនៃជនដទៃមានសេចក្តីប្រហែសធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ។*

យេ ច សីលេន សម្បន្នា, បញ្ញាយូបសមេ រតា;
អារកា វិរតា ធីរា, ន ហោន្តិ បរបត្តិយា ។

*ចំណែកពួកជនណា បរិបូណ៌ដោយសីល និងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់ ជាធីរជន អ្នកឆ្ងាយ អ្នកវៀរចាកបាប ធីរជននោះ មិនលុះតាមពាក្យជនដទៃទេ ។*

*គាថាទាំង ៣ នេះជាអភិសម្ពុទ្ធគាថា ។*

ពាក្យថា **ហ្វូងសត្វម្រឹគ** បានដល់ ហ្វូងម្រឹគច្រើនពាន់ ។ ពាក្យថា **បរិបូណ៌ដោយសីល** បានដល់ ដល់ព្រមដោយសីលដែលមកដោយអរិយមគ្គ ។ ពាក្យថា **និងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់** សេចក្តីថា ត្រេកអរនឹងការស្ងប់រម្ងាប់កិលេស ដោយបញ្ញាដែលមកដោយមគ្គនោះឯង បរិបូណ៌ដោយសីលយ៉ាងណា ក៏បរិបូណ៌ដោយបញ្ញាយ៉ាងនោះ ជាអ្នកត្រេកអរក្នុងការរម្ងាប់កិលេស ។ ពាក្យថា **ជាធីរជន អ្នកឆ្ងាយ អ្នកវៀរចាកបាប** បានដល់ បណ្ឌិតដែលឆ្ងាយ និងវៀរចាកកិរិយាធ្វើនូវបាប ។ ពាក្យថា **ធីរជននោះ មិនលុះតាមពាក្យជនដទៃទេ** សេចក្តីថា ធីរជនដែលមានសភាពបែបនោះជាព្រះសោតាបន្ន ជាអ្នកមានធម៌ត្រាស់ដឹងហើយ ដោយមគ្គញាណមួយវារៈ ដោយភាពជាអ្នកត្រេកអរនឹងការស្ងប់រម្ងាប់កិលេស និងភាពជាអ្នកឆ្ងាយផុតចាកបាប ទើបមិនជឿ និងកាន់យកពាក្យដែលបុគ្គលដទៃពោល ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះជាអ្នកប្រាកដជាក់ច្បាស់ដោយខ្លួនឯង ។ ព្រោះហេតុនោះ ព្រះសាស្តាទើបត្រាស់ថា

អស្សទ្ធោ អកតញ្ញូ ច, សន្ធិច្ឆេទោ ច យោ នរោ;
ហតាវកាសោ វន្តាសោ, ស វេ ឧត្តមបោរិសោ ។

**នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វាន[1]ផង កាត់នូវគ្រឿងតគឺវដ្តៈផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះជាឧត្តមបុរស ។**

(សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ អរហន្តវគ្គ សារិបុត្តត្ថេរវត្ថុ បិដកលេខ ៥២ ទំព័រ ៤២)

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

---

១. **អកតញ្ញូ** ក្នុងទីនេះ ប្រែថា អ្នកស្គាល់ព្រះនិព្វាន, ព្រះអរិយបុគ្គល ។

ដូចបទវិគ្គហៈថា **អកតំ និព្វានំ ជានាតីតិ > អកតញ្ញូ** បុគ្គលណាស្គាល់ព្រះនិព្វានដែលបច្ច័យមិនធ្វើ (មិនតាក់តែង) ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អកតញ្ញូ** ពាក្យនេះមកពី អកត + ញា + រូ ។

**តទា សីហោ អហោសិ** *សីហៈក្នុងកាលនោះ គឺ តថាគតនេះឯង ។*

*ចប់ ទុទ្ទុភជាតក ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត កុដិទូសកវគ្គ បិដកលេខ ៥៨ ទំព័រ ២០៩)*

*ថ្ងៃ ព្រហស្បតិ៍ ១២ កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៣ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*
*ដោយស.ដ.វ.ថ*